**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :២៤៨/០០៥/២០១៤

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

**សេចក្ដីសម្រេច**

លេខ : ១៤៧/០០១/២០១៤ កបធ.ច

ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៤ រ.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១៦ និង ០៤ នាទី ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងសហការី លើចំណុចមួយចំនួននៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ក្នុងសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្តីពី បទប្បញ្ញត្តិរួម មាន ៧ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ៧ ដែលចែងពីគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ វិសាលភាពនៃការអនុវត្ត បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឱ្យបំពេញមុខងារជាចៅក្រមនិងព្រះរាជអាជ្ញា និងការកំណត់ដាក់ចៅក្រមនិងព្រះរាជអាជ្ញាឱ្យស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពី ចៅក្រម ចែកចេញជា ១៤ ផ្នែក និង មាន ៦៦ មាត្រា គឺពីមាត្រា ៨ ដល់មាត្រា ៧៣ ដែលចែងពី បទប្បញ្ញត្តិទូទៅ ឋានន្តរស័ក្តិនិងថ្នាក់ ឯកសណ្ឋាន ប្រាក់បៀវត្សប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់និងការឈប់សម្រាក ការជ្រើសរើសចៅក្រម ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះចៅក្រម កាតព្វកិច្ចចៅក្រម ទណ្ឌកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការចូលនិវត្តន៍ ងារជាកិត្តិយស និងកិច្ចសច្ចាប្រណិធាន ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពី ព្រះរាជអាជ្ញា ចែកចេញជា ១៤ ផ្នែក និង មាន ៣២ មាត្រា គឺពីមាត្រា ៧៤ ដល់មាត្រា ១០៥ ដែលចែងពី បទប្បញ្ញត្តិទូទៅ ឋានន្តរស័ក្តិនិងថ្នាក់ ឯកសណ្ឋាន ប្រាក់បៀវត្សប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់និងការសម្រាកប្រចាំឆ្នាំ ការជ្រើសរើសព្រះរាជអាជ្ញា ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះព្រះរាជអាជ្ញា កាតព្វកិច្ចព្រះរាជអាជ្ញា ទណ្ឌកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការចូលនិវត្តន៍ ងារជាកិត្តិយស និងកិច្ចសច្ចាប្រណិធាន ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពី វិសមិតភាព មាន ២ មាត្រា គឺមាត្រា ១០៦ និង មាត្រា ១០៧ ដែលចែងពី វិសមិតភាពមុខងាររបស់ចៅក្រមនិងព្រះរាជអាជ្ញា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្តីពី អន្តរប្បញ្ញត្តិ មាន ៣ មាត្រា គឺពីមាត្រា ១០៨ ដល់មាត្រា ១១០ ដែលចែងពី ការធ្វើសមាហរណកម្មចៅក្រមនិងព្រះរាជអាជ្ញាក្នុងក្របខណ្ឌគ្រប់គ្រងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចូលទៅក្នុងក្របខណ្ឌចៅក្រមនិងព្រះរាជអាជ្ញា តាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែចៅក្រមនៃតុលាការយោធានិងព្រះរាជអាជ្ញាអមតុលាការយោធា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៦ ស្តីពី អវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ១១១ ដែលចែងពី បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទុកជានិរាករណ៍ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៦ ជំពូក ១១១ មាត្រា នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១**.- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២**.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល